

## ជំពូកទី ១២

# ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទ

នៅពេលកុមារកាន់តែមានម្ចាស់ការលើខ្លួនឯង ពួកគេជួបមនុស្សម្នាកាន់តែច្រើន ហើយពាក់ព័ន្ធជាមួយមនុស្សទាំងឡាយតាមវិធីច្រើនប្លែកៗពីគ្នា ។ ដូចគ្នាអញ្ចឹងដែរ ដែលពួកគេត្រូវតែរៀនបំលាស់ទីនៅជុំវិញលំនៅដ្ឋាន និងសហគមន៍ដោយសុវត្ថិភាព ហើយពួកគេត្រូវតែរៀនពីសុវត្ថិភាពផ្ទាល់ខ្លួនផងដែរ ។ ជំពូកនេះនិយាយពីការការពារកុមារពីការរំលោភបំពានផ្លូវភេទ ។ មើលទៅវាអាចជារឿងចម្លែកបន្តិចក្នុងការរកឃើញព័ត៌មានពីការរំលោភបំពានផ្លូវភេទក្នុងសៀវភៅនេះ ។ គួរឱ្យស្ដាយកុមារពិការ ដូចជាពិការភ្នែកអាចកាន់តែងាយរងគ្រោះចំពោះការរំលោភបំពានផ្លូវភេទជាងកុមារដែលមើលឃើញ ដូច្នេះការពិភាក្សាគ្នាអំពីករណីនេះ គឺជាការសំខាន់ណាស់ ។




វាពិតជាពិបាកមែនក្នុងការនិយាយអំពីការរំលោភបំពានផ្លូវភេទ ។ នៅតាមកន្លែងជាច្រើន :-

- មនុស្សទាំងឡាយកម្រនិយាយអំពីរឿងផ្លូវភេទណាស់ ។
- មនុស្សទាំងឡាយមិនចង់ជឿថាការរំលោភបំពានផ្លូវភេទកើតឡើងចំពោះកុមារតូចៗ ដូច្នេះទើបពួកគាត់មិនគិត ឬ និយាយអំពីបញ្ហានេះ ។
- ច្បាប់ ឬ ទំនៀមទម្លាប់បានកំណត់ថា តើនរណាគួរតែនិយាយទៅកាន់កុមារអំពីរឿងផ្លូវភេទអ្វីខ្លះដែលគួរតែលើកមកនិយាយ ហើយនៅពេលណាដែលការសន្ទនាប្រភេទនេះគួរតែកើតឡើង ។

**កុមារគ្រប់រូបគួរតែមានសុវត្ថិភាពពីការរំលោភបំពានផ្លូវភេទ។ ការថែរក្សាកុមារឱ្យសុខសាន្តចៀសផុតពីការរំលោភបំពានផ្លូវភេទ គឺជាការទទួលខុសត្រូវរបស់មនុស្សពេញវ័យគ្រប់រូប។**

## ការពិតមួយចំនួនអំពីការរំលោភបំពានផ្លូវភេទ

ការរំលោភបំពានផ្លូវភេទ គឺជាការទាក់ទងរវាងមនុស្សពេញវ័យម្នាក់ ( ឬ ជំទង់) និងកុមារតូចម្នាក់ ទោះជាដោយផ្ទាល់ ឬ មិនផ្ទាល់ក៏ដោយ ។ ការរំលោភបំពានផ្លូវភេទអាចកើតឡើងចំពោះកុមារណាម្នាក់ ។ ការរំលោភបំពានផ្លូវភេទកើតឡើងនៅគ្រប់បណ្តាសហគមន៍ ទាំងនៅក្នុងគ្រួសារអ្នកមាន និងអ្នកក្រីក្រ ។ ជារឿយៗការរំលោភបំពានផ្លូវភេទកើតឡើងភាគច្រើនចំពោះកុមារី តែក៏កើតមានចំពោះកុមារាផងដែរ ។

មានករណីជាច្រើនខុសៗគ្នាដែលកុមារអាចត្រូវបានរំលោភបំពានផ្លូវភេទ ។ ករណីខ្លះដែលកើតឡើងរួមមាន :-

**ការរំលោភបំពានផ្លូវភេទដែលពាក់ព័ន្ធដល់ការប៉ះពាល់រាងកាយរបស់កុមារ**

- ការថើបញ៉ក់ញី ឬ ឱបកុមារតាមបែបរួមភេទ ។
- ការរួមភេទតាមទ្វារមាស ឬ ទ្វារបន្ទោរបង់លាមក ។
- ការរួមភេទតាមមាត់ ( មាត់ទៅនឹងលិង្គ ឬ មាត់ទៅនឹងទ្វារមាស) ។
- ការស្ទាបអង្អែលប្រដាប់ភេទរបស់កុមារ ឬ ឱ្យកុមារស្ទាបអង្អែលប្រដាប់ភេទរបស់មនុស្សពេញវ័យ ។

**ការរំលោភបំពានផ្លូវភេទដែលមិនពាក់ព័ន្ធដល់ការប៉ះពាល់រាងកាយរបស់កុមារ**

- ការនិយាយអាសអាភាសដើម្បីធ្វើឱ្យកុមារភ័ន្តភាំង ឬ ធ្វើឱ្យអារម្មណ៍កុមារា-កុមារីរំភើបនឹងការរួមភេទ ។
- ការបង្ខំឱ្យកុមារស្តាប់ ឬ មើលមនុស្សដទៃរួមភេទ ។
- បង្ខំឱ្យកុមារថតរូបអាសអាភាស ។
- ការបង្ខំឱ្យកុមារធ្វើពេស្យាចារ ។

ការរំលោភបំពានផ្លូវភេទស្ទើរតែទាំងអស់កើតឡើងនៅពេលកុមារមានអាយុលើសពី 5 ឆ្នាំ តែវាក៏អាចកើតឡើងចំពោះកុមារតូចៗផងដែរ ។ កុមាររងគ្រោះស្ទើរតែទាំងអស់ត្រូវបានរំលោភបំពានដោយបុគ្គលណាម្នាក់ដែលពួកគេស្គាល់ ដូចជា សមាជិកម្នាក់នៃក្រុមគ្រួសារ ឬ ញាតិជិតខាងដែលមិនមែនដោយជនចម្លែកទេ ។ ជារឿយៗការរំលោភបំពានផ្លូវភេទបានកើតឡើងតាំងពីយូរមកហើយ ជួនកាលរាប់ឆ្នាំក៏មានដែរ ។

យើងមិនបានដឹងពិតប្រាកដថា ការរំលោភបំពានផ្លូវភេទមានលក្ខណៈទូទៅយ៉ាងណានោះទេ ដោយសារជាញឹកញាប់កុមារមិនហ៊ានប្រាប់នរណាម្នាក់ឡើយ ។ តែករណីនេះបានកើតឡើងរួចហើយចំពោះកុមារជាច្រើននាក់ក្នុងពិភពលោក យ៉ាងហោចណាស់មានកុមារម្នាក់ក្នុងចំណោមកុមារ 4 នាក់ បានរងគ្រោះដោយសារការរំលោភបំពាន ។



## ការរំលោភបំពានផ្លូវភេទបង្កទុក្ខទោសយូរអង្វែង

ទោះជាមានការពិបាកក្នុងការនិយាយពីការរំលោភបំពានផ្លូវភេទក៏ដោយ តែជាការសំខាន់ណាស់ត្រូវធ្វើយ៉ាងណាថា អ្នក ឬ នរណាម្នាក់ដែលអ្នកទុកចិត្តនិយាយជាមួយកូនអ្នក ។ ការពន្យល់ពីការរំលោភបំពានដល់កុមារតាមវិធីដែលពួកគេអាចយល់បាន វាមិនធ្វើឱ្យពួកគេព្រួយបារម្ភ និងមិនឈឺចាប់ឡើយ ។ វានឹងធ្វើឱ្យពួកគេកាន់តែមានសុវត្ថិភាពថែមទៀត ។

កាលពីនាងមានអាយុ 4 ឆ្នាំ **សាងហ្គីតា**ត្រូវបានបងប្រុសបង្កើតអាយុ 14 ឆ្នាំចាប់រំលោភ ។ នាងបានទៅរកឪពុកម្ដាយ ហើយប្រាប់គាត់តាមនិស្ស័យកូនក្មេងរបស់នាងថា បងប្រុសបានធ្វើឱ្យនាងឈឺចាប់ ។ ដំបូងឪពុកម្ដាយនាងបានគិតថា **សាងហ្គីតា**បានធ្វើឱ្យរាងកាយនាងជាំដោយខ្លួនឯង ។ **សាងហ្គីតា**មិនដឹងពាក្យត្រឹមត្រូវដើម្បីប្រើ តែនាងបានព្យាយាមនិយាយពន្យល់ឪពុកម្ដាយ ។

នៅទីបំផុតពេលឪពុកម្ដាយនាងយល់ពីអ្វីដែលបានកើតឡើង ពួកគាត់បានធ្វើអ្វីៗដែលល្អបំផុតដើម្បីបិទបាំងរឿងនោះ ។ **សាងហ្គីតា**ត្រូវបានហាមមិនឱ្យនិយាយអំពីរឿងបងប្រុសរំលោភបំពាននាងឡើយ ។ ឪពុកម្ដាយនាង "ដោះស្រាយបញ្ហា" ដោយការបញ្ជូនបងប្រុសនាងទៅសាលារៀនដែលមានកន្លែងរស់នៅ ។ ចំពោះឪពុកម្ដាយនាងរឿងហេតុត្រូវបានបញ្ចប់ ។

នៅពេល**សាងហ្គីតា**ធំពេញវ័យ ការរំលោភបំពានដោយបងប្រុសបានបង្កទុក្ខទោសយូរអង្វែងចំពោះនាង ។ នាងខ្លាចបុរស ហើយនាងមាអារម្មណ៍ថាវាជាកំហុសរបស់នាង ដែលបណ្ដាលឱ្យឪពុកម្ដាយបញ្ជូនបងប្រុសនាងទៅឆ្ងាយ ។ នៅពេលបងប្រុសនាងមកលេងផ្ទះ រៀងរាល់ពេលវិស្សមកាលនាងមិនអាចនិយាយរកគាត់ឡើយ ។ **សាងហ្គីតា**ជឿជាក់ក្នុងចិត្តថា នាងពិតជាមិនអាចរៀបការបានឡើយ ។ នាងបាននិយាយថា នាងមានអារម្មណ៍អាម៉ាស់និងខ្លាចមាន "ការឈឺចាប់" ម្ដងទៀត ។ នាងក៏មានសង្ឃឹមសំរាប់អនាគត និងជឿជាក់ចំពោះខ្លួនឯង ឬលទ្ធភាពរបស់នាងទៅអនាគតតិចតួចដែរ ។



នៅពេលនាងមានអាយុ 16 ឆ្នាំ **សាងហ្គីតា**បានចាប់ផ្ដើមនិយាយប្រាប់ម្ដាយមីងនាងដែលជាភ្នាក់ងារសុខាភិបាលអំពីរឿងរំលោភបំពានកាលពីកុមារភាព ។ នៅពេលនាងចែករំលែកអារម្មណ៍ និងការភ័យខ្លាចរបស់នាង នាងបានចាប់ផ្ដើមមានជំនឿទុកចិត្តលើខ្លួនឯងជាថ្មីម្ដងទៀត ។ នៅទីបញ្ចប់ជាមួយនឹងការគាំទ្រពីម្ដាយមីងនាង នាងអាចចែករំលែកអារម្មណ៍ជាមួយបងប្រុសនាងដែលបានអង្វរសុំឱ្យនាងមេត្តាអភ័យទោស ។ ឥឡូវនេះនាងកាន់តែសប្បាយចិត្ត ប៉ុន្តែនាងនៅតែមិនអាចនិយាយប្រាប់ឪពុកម្ដាយអំពីអារម្មណ៍របស់នាង ។

**សាងហ្គីតា**មានជោគវាសនាល្អ ដោយសារនាងអាចរកឃើញមនុស្សម្នាក់ដើម្បីនិយាយប្រាប់អំពីអារម្មណ៍របស់នាង ។ ជួនកាលជនរងគ្រោះដោយការរំលោភបំពានបានធ្វើមិនដឹងមិនឮថាគ្មានអ្វីបានកើតឡើងនោះទេ ។ ពេលខ្លះជនរងគ្រោះមិនចងចាំនូវអ្វីដែលបានកើតឡើងឡើយ ទាល់តែពួកគេចាប់ផ្ដើមនិយាយអំពី ហេតុអ្វីបានជាពួកគេមានអារម្មណ៍ភ័យខ្លាច ឬ មិនសប្បាយចិត្ត ។ ដល់ពេលធំពេញវ័យ បុគ្គលដែលត្រូវបានជនពាលរំលោភបំពានកាលនៅជាកុមារ មិនអាចនិយាយអំពីអារម្មណ៍របស់ខ្លួនគាត់ឡើយ ជារឿយៗពួកគាត់ក៏មិនអាចនិយាយទៅកាន់កូនៗពីរបៀបការពារខ្លួនពួកគេពីការរំលោភបំពានផងដែរ ។

## ហេតុអ្វីកូនខ្ញុំប្រឈមមុខនឹងភាពងាយរងគ្រោះនៃការរំលោភបំពានផ្លូវភេទ?

ជួនកាលមនុស្សពេញវ័យមានអារម្មណ៍ដូចជា ពួកគាត់មានសិទ្ធិប្រើប្រាស់កុមារសំរាប់ការរួមភេទ ។ ពេលខ្លះកុមារធំៗមិនបានដឹងខ្លួនថាពួកគេកំពុងធ្វើអ្វីមួយអាក្រក់ឡើយ ។

កុមារគ្រប់រូបងាយប្រឈមមុខនឹងភាពងាយរងគ្រោះចំពោះការរំលោភបំពានផ្លូវភេទ ពីព្រោះពួកគេជឿទុកចិត្ត ហើយពឹងផ្អែកលើមនុស្សធំ និងកុមារធំៗសំរាប់ការថែទាំ ។ ប្រការនេះធ្វើឱ្យកុមារតូចៗមានការពិបាកក្នុងការនិយាយថា "ទេ" ទៅកាន់ពួកមនុស្សធំ ។ កុមារតូចៗមានការអភិវឌ្ឍបំណិនការគិតតិចតួច និងមិនដឹងថាអ្វីទៅជាអាកប្បកិរិយាដែលអាចទទួលយកបានរបស់ពួកមនុស្សធំ ។

កុមារដែលមានពិការភាពគឺប្រឈមមុខនឹងភាពងាយរងគ្រោះចំពោះការរំលោភបំពានផ្លូវភេទ ច្រើនជាងកុមារដែលគ្មានពិការភាព ពីព្រោះជាញឹកញាប់កុមារពិការត្រូវតែពឹងផ្អែកលើមនុស្សដទៃសំរាប់ការថែទាំ ។ សរុបសេចក្ដីទៅ កុមារពិការភ្នែក ឬ កុមារដែលមិនអាចមើលឃើញច្បាស់ :-

- បំណិនប្រាស្រ័យទាក់ទងអភិវឌ្ឍបានតិចតួច ។ ប្រការនេះធ្វើឱ្យពួកគេពិបាកយល់នូវអ្វីដែលអ្នកប្រាប់អំពីសុវត្ថិភាពរបស់ពួកគេ ។ វាក៏អាចធ្វើឱ្យអ្នកកាន់តែពិបាកយល់ផងដែរ នៅពេលកុមារព្យាយាមប្រាប់អ្នកពីការរំលោភបំពាន ។
- អាចមានព័ត៌មាន/ដឹងតិចតួចអំពីរាងកាយរបស់ពួកគេ និងភាពខុសគ្នារវាងរាងកាយ "ក្មេងប្រុស" និង "ក្មេងស្រី" ជាងកុមារដែលអាចមើលឃើញ ។
- ខ្វះព័ត៌មានសំខាន់ៗដូចជា មើលមុខនរណាម្នាក់ ជួនកាលអាចជួយឱ្យកុមារដឹងអាកប្បកិរិយានៃសុវត្ថិភាពសង្គម ។

ជនពាលគ្រប់រូបមិនប្រើកម្លាំងបាយក្នុងការរំលោភបំពានផ្លូវភេទជានិច្ចនោះទេ ។ ពួកគេអាចប្រើវិធី :-

- ពាក្យសម្ដីបញ្ចុះបញ្ចូល និងផ្អែមល្ហែម ។
- បញ្ឆោតឱ្យវង្វេង ។
- គំរាមគំហែង និង សម្លុត ។

លទ្ធផលនៃការរំលោភបំពាន គឺនៅតែជាអំពើហឹង្សា និង បង្កភាពខូចខាតចំពោះកុមារ ។






# ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទ

## ➤ វិធីជួយកូនរៀនអំពីរាងកាយរបស់គេ ( ប្រុស ឬ ស្រី)

កុមារមានអាយុ 18 ខែអាចចាប់ផ្តើមរៀនឈ្មោះចំណែកនៃរាងកាយរបស់ខ្លួន ។ នៅពេលកូនអ្នកមានអាយុពី 3 ទៅ 5 ឆ្នាំ ចូរបង្រៀនកូនអំពីប្រដាប់បន្តពូជ និងចំណែកលាក់បាំងដទៃទៀតនៃរាងកាយ និងអំពីភាពខុសប្លែកគ្នារវាងរាងកាយ "ក្មេងស្រី" និង "ក្មេងប្រុស" ។



ការបង្រៀនអាចកើតឡើងតាមធម្មតា ឧទាហរណ៍នៅពេលអ្នកងូតទឹកឱ្យកូន ។ កុមារពិការភ្នែក ឬ ដែលមានបញ្ហាគំហើញអាចត្រូវការឱ្យជួយបន្ថែមក្នុងការរៀនអំពីចំណែកនៃរាងកាយ ។ សូមអានទំព័រ 102 និង 103 សំរាប់សកម្មភាពដែលនឹងជួយដល់កុមារ ។ ការប្រើកូនតុក្កតាដើម្បីបង្ហាញសកម្មភាពពិតប្រាកដ អាចមានប្រយោជន៍ក្នុងការបង្រៀនអំពីចំណែកនៃរាងកាយផងដែរ ។

## ➤ វិធីជួយកូនឱ្យយល់អំពីចំណែកលាក់បាំងនៃរាងកាយរបស់គេ ( ប្រុស ឬ ស្រី)

ចូរពន្យល់ប្រាប់កូនថា ចំណែកខ្លះនៃរាងកាយគឺមានភាពលាក់បាំងជាងចំណែកដទៃទៀត ។ ចូរពន្យល់ប្រាប់កូនថាមនុស្សម្នាមិនគួរប៉ះពាល់ប្រដាប់បន្តពូជ ឬ ចំណែកលាក់បាំងនៃរាងកាយកុមារឡើយ ហើយកូនអ្នកមិនគួរប៉ះពាល់ចំណែកលាក់បាំងរបស់អ្នកដទៃ ទោះបីជានរណាម្នាក់បង្គាប់ឱ្យប៉ះវាក៏ដោយ ។

ចូរចងចាំក្នុងការពន្យល់ប្រាប់ផងដែរថា ការរំលោភបំពានមិនពាក់ព័ន្ធការប៉ះពាល់រាងកាយគ្រប់ករណីនោះទេ ។



## ➤ វិធីជួយកូនឱ្យរៀននិយាយថា "ទេ"

ចូរជួយកូនអ្នកឱ្យចេះជឿទុកចិត្តលើអារម្មណ៍ខ្លួនឯង និងលើកទឹកចិត្តគេឱ្យនិយាយទៅកាន់អ្នកអំពីអារម្មណ៍របស់គេ។

ស្នើសុំឱ្យកូនប្រាប់អ្នក ឬ មនុស្សធំណាម្នាក់ភ្លាមៗ បើសិនជានរណាមួយប្រាប់ឱ្យកូនអ្នកធ្វើអ្វីមួយដែលគេមានអារម្មណ៍មិនស្រណុកចិត្តនឹងធ្វើ។




ចូរជួយកូនអ្នកឱ្យហាត់និយាយថា "ទេ"។ មុនដំបូងសាកល្បងប្រឌិតស្ថានភាពដែលធ្វើឱ្យកូនចង់និយាយថា "ទេ"។




ក្រោយមកទៀត ចូរនិយាយអំពីការនិយាយថា "ទេ" និងកន្លែងដែលកូនអ្នកអាចទៅរកការជួយ។



### ➤ វិធីជួយកូនឱ្យយល់ថា មិនត្រូវស្តាប់បង្គាប់មនុស្សធំជានិច្ចនោះទេ




ចូរបង្រៀនកូនអ្នកថា នាងគួរតែស្រែក "ទេ!ទេ!" ស្រែកឱ្យខ្លាំងអស់សម្លេង, ខាំ, និងតស៊ូប្រតាយប្រតប់ បើមនុស្ស ធំ ឬ ក្មេងធំណាម្នាក់ព្យាយាមរំលោភបំពាន ឬ វាយដំ ឬ និយាយពាក្យអាសអាភាសទៅរកនាង។



## ➤ វិធីជួយកូនឱ្យយល់អំពីរឿងសំងាត់

ចូរនិយាយអំពីរឿងសំងាត់ដែលល្អ និងមិនល្អ។




ចូរពន្យល់ប្រាប់កូនអ្នកថា បើនរណាម្នាក់គំរាមគំហែងនាងកុំឱ្យប្រាប់អំពីរឿងសំងាត់អ្វីមួយ នោះនាងត្រូវតែប្រាប់អ្នក។ ជនពាលអាចនិយាយបែបនេះ **“នេះជារឿងសំងាត់របស់យើង។ បើឯងប្រាប់នរណាម្នាក់ អញនឹងសម្លាប់ឯងចោល ឬ សម្លាប់អ្នកណាដែលឯងនិយាយរឿងនោះប្រាប់។ ហើយអញនឹងប្រាប់មនុស្សគ្រប់គ្នាពីរឿងអាក្រក់ដែលឯងបានធ្វើ”**។ ចូរធ្វើឱ្យកូនអ្នកទុកចិត្តខ្លួនឯងឡើងវិញ ថាគ្មានអ្វីដែលអាក្រក់នឹងកើតឡើងឡើយ បើនាងប្រាប់រឿងសំងាត់ដល់អ្នក។ កុមារត្រូវការដឹងថា ជនពាលគំរាមគំហែងបែបនេះដោយសារជនពាលខ្លួនឯងបានធ្វើអ្វីមួយអាក្រក់ មិនមែនកុមារទេ។




## ➤ ចូរគោរពចំពោះភាពឯកជននៃតម្រូវការផ្ទាល់ខ្លួនរបស់កូន នៅខណៈដែលកូនងូតទឹក ឬ ស្លៀកពាក់

កុមារពិការភ្នែកអាចរកឃើញថាវាពិបាកក្នុងការស្វែងយល់នូវគំនិតនៃចំណែកលាក់បាំងនៃរាងកាយ ពីព្រោះគេ ឬ នាងត្រូវការឱ្យជួយនៅក្នុងសកម្មភាពយ៉ាងច្រើន។ តែអ្នកអាចលើកទឹកចិត្តកូនឱ្យប្រាប់អ្នក នៅពេលណាកូនមិនត្រូវការឱ្យអ្នកជួយ។



## តើខ្ញុំអាចដឹងដោយរបៀបណាថា កូនខ្ញុំត្រូវបានជនពាលរំលោភបំពានផ្លូវភេទ?

នៅពេលកុមារតូចៗត្រូវបានរំលោភបំពាន ពួកគេប្រហែលជាខ្លាចមិនហ៊ានប្រាប់អ្នក ពីព្រោះជនពាលបានព្រមានកូនអ្នកមិនឱ្យនិយាយអ្វីមួយ ឬដោយសារកូនអ្នកខ្លាចថា នាងបានធ្វើអ្វីមួយខុស ឬកុមារអាចខ្វះបំណិនប្រាស្រ័យទាក់ទងដើម្បីនិយាយប្រាប់ពីអ្វីដែលបានកើតឡើង។

ដោយសារតែកុមារមិនសូវប្រាប់ពីរឿងរំលោភបំពាន អ្នកត្រូវការសង្កេតមើលសញ្ញាសម្គាល់នានា ដែលអាចទៅរួច។ សញ្ញាសម្គាល់ដូចតទៅនេះ មិនប្រាកដថាជាលទ្ធផលនៃការរំលោភបំពានជានិច្ចឡើយ តែវាជាមូលហេតុបណ្ដាលគួរឱ្យព្រួយបារម្ភ ជាពិសេសបើសិនជាកុមារបង្ហាញករណីមួយចំនួនដូចខាងក្រោម។

**សញ្ញាខ្លះៗដែលចម្លែកលើរាងកាយរួមមាន :-**

- ការឈឺចាប់គ្មានមូលហេតុ ហើម ឬ ឈាមមាត់, ឈាមនៅប្រដាប់បន្តពូជ ឬ នៅជុំវិញទ្វារបន្ទោរបង់លាមក។
- ខោទ្រនាប់រហែក ឬ ប្រឡាក់ឈាម។
- លំបាកជុះនោម ឬ លំបាកបន្ទោរបង់លាមក។
- ជំងឺឆ្លងតាមរយៈការរួមភេទ (កាមរោគ)។
- ស្នាមជាំៗ។
- ឈឺក្បាល ឬ ឈឺពោះ។

**កុមារដែលត្រូវបានជនពាលរំលោភបំពានផ្លូវភេទ អាច :-**

- ឈប់ងូតទឹក ឬ លាងសំអាតខ្លួនឯងញឹកញាប់ជាងទម្លាប់ធម្មតា។
- លេងជាមួយកុមារដទៃទៀត ឬ ប្រដាប់លេងតាមរបៀបរួមភេទ។
- ដឹងរឿងរួមភេទច្រើនជាងក្មេងៗដែលមានអាយុស្រករគ្នា។




**កុមាររងគ្រោះដោយអំពើហិង្សា រួមទាំងការរំលោភបំពានផ្លូវភេទ អាច :-**

- ហាក់ដូចជាភ័យខ្លាច, អារម្មណ៍ងាយប្រែប្រួល, និងប្រយ័ត្នប្រយែង ឬ ស្រាប់តែចៀសវាង ឬ ខ្លាចនរណាមួយ ឬ កន្លែងណាមួយភ្លាមមួយរំពេច។
- ចង់នៅតែជាមួយឪពុកម្ដាយរបស់ខ្លួនគ្រប់ពេលវេលា។
- មានភាពអាថិកំបាំង ឬ ចង់តែនៅម្នាក់ឯងស្ទើរគ្រប់ពេលវេលា។
- ចាប់ផ្ដើមសំដែងឫកពារដូចកូនក្មេងតូច ជាចរិតកូនក្មេងបៀមដៃ។
- ព្យាយាមរត់គេចចេញពីផ្ទះ។
- មានអារម្មណ៍សោកសៅស្ទើរគ្រប់ពេលវេលា ឬ បង្ហាញថាអារម្មណ៍មិននៅក្នុងខ្លួនទាល់តែសោះ។
- ពិបាកដេក ពីព្រោះយល់សប្ដិអាក្រក់ និងខ្លាចទីងងឹត។

**បើសិនជាអ្នកសង្ស័យថាមានការរំលោភបំពាន សូមព្យាយាមធ្វើចិត្តឱ្យស្ងប់។ ចូរស្វែងរកព័ត៌មានឱ្យបានច្រើនដោយសាកល្បងសួរកូនថា នាងមានអារម្មណ៍យ៉ាងណា។ វាអាចជួយផងដែរដើម្បីបង្កើតស្ថានភាពលេង ដែលលើកទឹកចិត្តកូនឱ្យបង្ហាញអ្នកនូវអ្វីដែលបានកើតឡើង ឬក៏អ្វីដែលកូនដឹង។ ចូរយកចិត្តទុកដាក់ស្ដាប់ដោយប្រុងប្រយ័ត្ន និងធ្វើយ៉ាងណាឱ្យកូនដឹងថាអ្នកជឿនាង។**

## បើសិនជាកូនរបស់អ្នកត្រូវបានជនពាលរំលោភបំពានផ្លូវភេទ

បើសិនជាកូនរបស់អ្នកត្រូវបានជនពាលរំលោភបំពានផ្លូវភេទ អ្នកអាចជួយបាន បើសិនជាអ្នក :-

- ជឿជាក់នូវអ្វីដែលនាងនិយាយ ។ កុមារកម្រនឹងប្រឌិតអំពីការរំលោភបំពានផ្លូវភេទណាស់ ។
- ចូរលើកទឹកចិត្តកូនដែលបានប្រាប់អ្នក ។ ក្មេងត្រូវការដឹងថាពួកគេបានធ្វើអ្វីៗត្រឹមត្រូវដោយនិយាយប្រាប់អំពីការរំលោភបំពាន ។
- ចូរធ្វើឱ្យនាងទុកចិត្តឡើងវិញថារឿងរំលោភបំពានមិនមែនជាកំហុសរបស់នាងឡើយ ហើយអ្នកមិនខឹងនាងទេ ។
- ចូរការពារសុវត្ថិភាពរបស់កូន ។ ចូរព្យាយាមទប់ស្កាត់ការទាក់ទងរវាងកូន និងជនពាលនៅពេលអនាគត ។ បើសិនជាប្រការនេះមិនអាចធ្វើបាន អ្នកត្រូវធ្វើយ៉ាងណា ឬ ត្រូវមាននរណាម្នាក់ដែលដឹងរឿងកើតឡើងពីមុននៅជាមួយកូនជានិច្ច ខណៈពេលមានវត្តមានរបស់ជនពាល ។
- ចូរព្យាបាលបញ្ហាសុខភាពរាងកាយដែលបណ្តាលមកពីការរំលោភបំពាន ។ ព្យាយាមនាំកូនទៅធ្វើតេស្តជំងឺកាមរោគ ទោះបីជាកូនមិនមានរោគសញ្ញាអ្វីចម្លែកក៏ដោយ ។ ជំងឺកាមរោគខ្លះមិនបង្ហាញរោគសញ្ញាអ្វីឡើយ ឬ រោគសញ្ញានេះមិនបង្ហាញពេលរឿងហេតុកើតឡើងភ្លាមនោះទេ ទាល់តែកុមារធំទើបរោគសញ្ញានោះបង្ហាញឡើង ។

ក្នុងនាមជាឪពុកម្តាយ អ្នកត្រូវការការជួយផងដែរ ។ ឪពុកម្តាយមានអារម្មណ៍រំជួលចិត្តយ៉ាងខ្លាំង រួមមាន ការមិនជឿជាក់, ខឹងម៉ូរម៉ៅ, និងសោកសៅយ៉ាងខ្លាំង នៅពេលពួកគាត់ដឹងថាកូនរបស់ខ្លួនត្រូវបានជនពាលរំលោភបំពាន ។ ឪពុកម្តាយអាចបន្ទោសខ្លួនឯង ឬ បន្ទោសគ្នាទៅវិញទៅមកនូវអ្វីដែលបានកើតឡើងចំពោះកូន ។ វាអាចជួយអ្នកឱ្យបានរសាយចិត្តក្នុងការនិយាយប្រាប់នរណាម្នាក់ដែលអ្នកទុកចិត្តអំពីអារម្មណ៍ទាំងនេះ ។ អ្នកត្រូវមានចិត្តអំណត់ចំពោះខ្លួនឯង ។ វាអាចចំណាយពេលយ៉ាងយូរដើម្បីរំសាយអារម្មណ៍ទាំងនេះ ។

## វិធីធ្វើឱ្យកុមារគ្រប់រូបកាន់តែមានសុវត្ថិភាពនៅក្នុងសហគមន៍

កម្មវិធីនៅសាលារៀន ឬ នៅសហគមន៍អាចបង្រៀនសហគមន៍ទាំងមូលពីការរំលោភបំពានផ្លូវភេទ ។ ការសំដែងឆាកល្ខោន ឬ រឿងខ្លីៗអំពីផលប៉ះពាល់នៃការរំលោភបំពាន ពេលខ្លះអាចធ្វើឱ្យមនុស្សមានការងាយស្រួលជជែកគ្នាជាក្រុមអំពីការរំលោភបំពាន ។

កំណត់ផែនការរៀបចំសិក្ខាសាលាសំរាប់ក្រុមឪពុកម្តាយ ដើម្បីជួយពួកគាត់រៀនពីវិធីនៃការប្រាស្រ័យទាក់ទងនានា ជាមួយកុមារតូចៗអំពីការរំលោភបំពានផ្លូវភេទ ។

រៀបចំការប្រជុំដើម្បីសំរេចចិត្តពីរបៀបដែលសហគមន៍របស់អ្នកអាចឆ្លើយតបទៅនឹងករណីរំលោភបំពានផ្លូវភេទ ។ សហគមន៍ខ្លះបានផ្តល់យោបល់ថា នាំគ្នាជួបជុំនៅមុខផ្ទះជនពាលដែលពួកគាត់ស្គាល់ ដើម្បីធ្វើឱ្យជនពាលទាំងនោះអាម៉ាស់ មុខជាសាធារណៈ ។

